# សំណួរដែលសួរញឹកញាប់

### Q1: តើអ្វីជាបណ្ណឥណពន្ធវីសា Classic ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់?

A: បណ្ណឥណពន្ធវីសា Classic ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ គឺជាបណ្ណឥណពន្ធស្តង់ដារសម្រាប់គណនីប្រតិបត្តិការប្រចាំថ្ងៃ។ បណ្ណនេះផ្តល់ជូនអតិថិជននូវភាពងាយស្រួលក្នុងការដកប្រាក់តាមបណ្តាញដែលមានស្លាកសញ្ញា Visa នៅទូទាំងពិភពលោក ហើយលោកអ្នកក៏អាចធ្វើការទិញទំនិញតាមអ៊ីនធឺណែត នៅក្នុងស្រុក ក្រៅស្រុក ឬតាមទូរស័ព្ទដោយកាត់ចេញពីសមតុល្យដែលលោកអ្នកមាននៅក្នុងគណនី។ ដោយដឹងថាលោកអ្នកកំពុងធ្វើការចំណាយប្រាក់ដោយផ្ទាល់ចេញពីគណនីប្រតិបត្តិការរបស់ខ្លួន ទើបធនាគារផ្តល់ជូនអតិថិជននូវជម្រើសក្នុងការគ្រប់គ្រងប្រាក់បានយ៉ាងល្អប្រសើរទៅលើការចំណាយរបស់ខ្លួន។

### Q2: តើមានបណ្ណប្រភេទអ្វីខ្លះ?

A: បណ្ណឥណពន្ធវីសា Classic ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ សម្រាប់អតិថិជនដែលមានគណនីដូចខាងក្រោម៖

- គណនី The ONE
- គណនីមូលប្បទានប័ត្រផ្ទាល់ខ្លួន

បណ្ណឥណពន្ធវីសា Premier ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ មានប្រើសម្រាប់អតិថិជនដែលមានគណនី Premier។

### Q3: តើបណ្ណឥណពន្ធវីសា Classic ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ដំណើរការយ៉ាងដូចម្តេច?

A: បណ្ណឥណពន្ធវីសា Classic ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ប្រើបាន៖

- ធ្វើប្រតិបត្តិការយ៉ាងមានសុវត្ថិភាពនៅតាមហាងដែលមានស្លាកសញ្ញា Visa នៅទូទាំងពិភពលោក រួមទាំងក្នុងប្រទេសផងដែរ បញ្ជារទិញទំនិញអនឡាញ តាមទូរស័ព្ទ និង ទូរសារ
- ដកប្រាក់នៅតាមម៉ាស៊ីន ATM ដែលមានស្លាកសញ្ញា Visa និង PLUS នៅទូទាំងពិភពលោក (ទូម៉ាស៊ីន ATM ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ គឺជាផ្នែកមួយនៃបណ្តាញទូម៉ាស៊ីន PLUS ATM)។
- ចំនួនដែលធ្វើប្រតិបត្តិការនឹងត្រូវកាត់ចេញដោយផ្ទាល់ពីគណនីរបស់លោកអ្នកដែលភ្ជាប់ជាមួយបណ្ណនោះក្នុងថ្ងៃដដែល ធ្វើប្រតិបត្តិការ។

### Q4: តើបណ្ណឥណពន្ធវីសា Classic ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ មានសុវត្ថិភាពកម្រិតណា?

A: បណ្ណឥណពន្ធវីសា Classic ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ មានសុវត្ថិភាពជាច្រើនមានដូចជា៖

- បង្កប់ប្រព័ន្ធ EMV-Dynamic ផ្ទៀងផ្ទាត់ទិន្នន័យជាមួយ Smart Chip ដែលផ្តល់សុវត្ថិភាពកម្រិតស្តង់ដារពិភពលោក
- ប្រព័ន្ធត្រួតពិនិត្យតាមដានការក្លែងបន្លំជាប្រចាំដើម្បីកំណត់សកម្មភាពដែលគួរឱ្យសង្ស័យ និងជួយទប់ស្កាត់ប្រតិបត្តិការដែលមិនមានការអនុញ្ញាត
- ជម្រើសបិទបណ្ណរបស់លោកអ្នកជាអចិន្ត្រៃយ៍ ឬបិទជាបណ្តោះអាសន្ន នៅពេលដែលលោកអ្នកជូនដំណឹងមកកាន់ធនាគារភ្លាមៗក្នុងករណីដែលបណ្ណត្រូវគេលួច បាត់បង់ ឬបាត់ពីកន្លែងដែលទុក និង
- បណ្ណថ្មី និងបណ្ណជំនួស ត្រូវបានផ្តល់ជូនក្នុងលក្ខខណ្ឌផ្អាកការប្រើប្រាស់ជាបណ្តោះអាសន្ន ប៉ុន្តែដើម្បីការពារមិនឱ្យមានហានិភ័យនៃប្រតិបត្តិការដែលមិនមានការអនុញ្ញាតតាមរយៈហត្ថលេខា។ លោកអ្នកអាច

សំណួរដែលសួរញឹកញាប់

ដំណើរការប្រើប្រាស់បណ្ណបានយ៉ាងងាយស្រួល និងភ្លាមៗដោយគ្រាន់តែទូរសព្ទមកផ្នែកសេវាអតិថិជនតាមរយៈលេខ៖ +855 23 999 000។

**Q5: តើខ្ញុំគួរធ្វើអ្វីខ្លះ ប្រសិនបើបណ្ណឥណពន្ធវីសា Classic ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ របស់ខ្ញុំ បានបាត់ ត្រូវគេលួច ភ្លេចបាត់ ឬប្រសិនបើ PIN របស់ខ្ញុំត្រូវបានលួចប្រើនោះ?**

A: សូមជូនដំណឹងមកកាន់ធនាគារភ្លាមតាមរយៈផ្នែកសេវាអតិថិជនតាមទូរសព្ទលេខ +855 23 999 000 ដែលរង់ចាំទទួលការឆ្លើយតប 24 ម៉ោង។

**Q6: តើកម្រិតការចំណាយសម្រាប់បណ្ណឥណពន្ធវីសា Classic ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ របស់ខ្ញុំមានចំនួនប៉ុន្មាន?**

A: កម្រិតការចំណាយប្រចាំថ្ងៃរបស់លោកអ្នកគឺយោងតាមសមតុល្យទឹកប្រាក់ដែលមាននៅក្នុងគណនីដែលលោកអ្នកបានភ្ជាប់ ឬដកនៅតាមម៉ាស៊ីន ATM របស់ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ រហូតដល់ 2,000 ដុល្លារអមេរិក និង 9,999 ដុល្លារអាមេរិកសម្រាប់ប្រតិបត្តិការតាមប្រព័ន្ធអេឡិចត្រូនិកសម្រាប់អតិថិជនទូទៅរបស់ធនាគារ។

ប្រសិនបើចាំបាច់ លោកអ្នកអាចធ្វើការពិភាក្សាជាមួយយើងខ្ញុំអំពីលទ្ធភាពនៃការបង្កើន ឬបន្ថយការកម្រិតចំនួនកំណត់នៃការចំណាយរបស់លោកអ្នក។ សូមទំនាក់ទំនងមកកាន់ធនាគារ ប្រសិនបើលោកអ្នកមានតម្រូវការ។

**Q7: ខ្ញុំបានបាត់បណ្ណឥណពន្ធ ហើយខ្ញុំបានទទួលបណ្ណថ្មី។ តើបណ្ណនោះនឹងត្រូវធ្វើបច្ចុប្បន្នភាពដោយស្វ័យប្រវត្តិជាមួយនឹងការកំណត់នៃបណ្ណចាស់របស់ខ្ញុំសម្រាប់ការដកប្រាក់នៅក្រៅប្រទេស និងចំនួនកម្រិតនៃការចំណាយប្រចាំថ្ងៃរបស់ខ្ញុំដែរ ឬទេ?**

A: គ្មានទេ! ធនាគារនឹងចេញបណ្ណថ្មីជូនដូចទៅនឹងការកំណត់លំនាំដើម (default settings) លុះត្រាតែលោកអ្នកបានបញ្ជាក់នៅពេលដែលស្នើសុំបណ្ណថ្មី។ សូមមើលសំណួរមុនៗសម្រាប់ជាការកំណត់លំនាំដើមដើម ឬសូមទំនាក់ទំនងមកកាន់ធនាគារ ប្រសិនបើលោកអ្នកមានតម្រូវការ។